**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ រវាង

លោក **ហែម សក្ខណា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៩៣៧៤០៥ ដែលមានតួនាទី **នាយកគ្រប់គ្រងទូទៅ** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **អេនមិន បាសាក់រីវើរ** ដែលមានអាសយដ្ឋានស្ថិតនៅ **អាគារលេខ អិន២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ** ធ្វើជាមួយនិង ៖

- លោកស្រី **អ៊ុំ សៅឌីណា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ១៥០២៧៧៩១៥ ដែលមានតួនាទីជាជំនួយការប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។
- លោកស្រី **គួច ឆារ៉ា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ១៥០៨២៨៣៨៣ ដែលមានតួនាទីជាមេចុងភៅអាហារជប៉ុន និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។
- លោកស្រី **សួច ណារ៉ុខ** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១១១៣៣៤៣ ដែលមានតួនាទីជាមេចុងភៅអាហារអឺរ៉ុប និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។

ភាគីទាំងបីបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

០១- <u>រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖</u>

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០២០ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ១៩។

០២- <u>ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖</u>

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

០៣- <u>កាលបរិច្ឆេទចូលបម្រើការងារវិញ៖</u>

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០

| **តំណាងភាគីនិយោជិត** | | | **តំណាងភាគីនិយោជក** |
| --- | --- | --- | --- |
| **លោកស្រី អ៊ុំ សៅឌីណា** | **កញ្ញា គួច ឆារ៉ា** | **លោកស្រី សួច ណារ៉ុខ** | **លោក ហែម សក្ខណា** |

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អេន&អិម បាសាក់ រីវើរ ខូ លីមីធីត H&M BASSAC RIVER Co., Ltd. KINGDOM OF CAMBODIA